## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្ដឹង

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ[1]។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..............................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..............................................

លេខទូរស័ព្ទ៖ ..........................................................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

---

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ ដូច្នេះ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគី។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ប្រសិនបើពុំមានការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនទេ ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅឋានរបស់ដើមចោទជាអាទិ៍។ ហេតុនេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ដើមចោទមានបំណងធ្វើការបញ្ជូនទៅកាន់ទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ដើមចោទជាអាទិ៍ គឺមានភាពចំបាច់ក្នុងការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូននៅក្នុងលិខិតពាក្យបណ្ដឹងជាអាទិ៍។

## សូមគោរពជូន

## លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ[4] ៖

(១) បង្គាប់ឲ្យចុងចម្លើយប្រគល់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ [5] ឲ្យទៅដើមចោទ។

(២) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។ [6]

(៣) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។[7]

---

[3] ការដាក់ពាក្យបណ្តឹងត្រូវធ្វើទៅតុលាការដែលមានសមត្ថកិច្ច (សមត្ថកិច្ចសាលាជម្រះក្តី) (មាត្រា ៨ មាត្រា ៩ ជាអាទិ៍នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ដោយសារតែលំនៅឋានរបស់ចុងចម្លើយ និង កន្លែងដែលអចលនវត្ថុស្ថិតនៅ គឺនៅរាជធានីភ្នំពេញទាំងពីរ ដូច្នេះ តុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងរាជធានីភ្នំពេញ ( ក្រមនីតិវិធិរដ្ឋប្បវេណីមាត្រា ៨ ចំណុច ក និង មាត្រា ៩ ចំណុច ឆ)។

[4] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[5] ឧបសម្ព័ន្ធ ជាឯកសារមួយដែលបានបង្កើតដើម្បីដាក់បញ្ចូលព័ត៌មាននោះ ហើយជាផ្នែកតែមួយនៃឯកសារដើម។ ឧបសម្ព័ន្ធ គឺគ្រាន់តែជាការសរសេរដើម្បីធ្វើការសរុបនូវខ្លឹមសារមួយផ្នែកដាក់នៅក្នុងទំព័រចុងក្រោយ ដោយផ្អែកលើការពិចារណាអំពីភាពងាយស្រួលនៃការអានខ្លឹមសារទាំងស្រុងនៃឯកសារដើម។ ដូច្នេះហើយ ប្រសិនបើ "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" ត្រូវបានដកស្រង់ខ្លឹមសារទៅដាក់នៅក្នុងឧបសម្ព័ន្ធ នោះមានន័យថា គេគ្រាន់តែបានយកខ្លឹមសារមួយផ្នែកដែលមានភាពចាំបាច់ត្រូវសរសេរនៅក្នុង "ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" មកសរសេរសរុបដាក់នៅក្នុងទំព័រចុងក្រោយតែប៉ុណ្ណោះ ហើយ <u>"ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ" ក៏រួមបញ្ចូលទាំងឧបសម្ព័ន្ធ</u> ផងដែរ។

រីឯឯកសារភ្ជាប់ ជាឯកសារដែលគេបានយកមកភ្ជាប់ជាមួយឯកសារដើម ហើយឯកសារភ្ជាប់នេះមិនមែនជាផ្នែកមួយនៃឯកសារដើមឡើយ។

[6] អ្នកចុះបញ្ជី គឺជាមន្ត្រីសុរិយោដី ( ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី (តទៅនៅពេលដែលហៅដោយសង្ខេបថា "ប្រកាសអន្តរក្រសួង" ដែលសំដៅទៅលើប្រកាសអន្តរក្រសួងនេះ ) មាត្រា ៩០) មិនមែនជាចុងចម្លើយទេ។ ចុងចម្លើយមានកាតព្វកិច្ចធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី (មាត្រា ១០ កថាខណ្ឌទី ១ នៃប្រកាសអន្តរក្រសួង) ពោលគឺ ចុងចម្លើយមានកាតព្វកិច្ចមិនលើសពីការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជីឡើយ។ នៅពេលដែលសាលក្រមបង្គាប់ទៅចុងចម្លើយអំពីការត្រូវធ្វើការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជី (ធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី) បាន ចូលជាស្ថាពរ នឹងត្រូវបានចាត់ទុកថា ចុងចម្លើយបានធ្វើការបង្ហាញឆន្ទៈនៅពេលចូលជាស្ថាពរនោះ (មាត្រា ៥២៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ជាងនេះទៅទៀត ដើមចោទដែលជាអ្នកមានសិទ្ធិចុះបញ្ជី នៅពេលដែលទទួលបានសាលក្រមស្ថាពរដែលបង្គាប់អំពីនីតិវិធីចុះបញ្ជីមកធ្វើជាលិខិតអនុវត្ត គឺអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន (មាត្រា ១០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ មន្ត្រីសុរិយោដីនឹងមានកាតព្វកិច្ចចុះបញ្ជីនៅពេលដែលចាប់ផ្តើមមានពាក្យសុំ (ប្រកាសដដែល មាត្រា ៦ កថាខណ្ឌទី ២)។ វានឹងមិនអាចទៅរួចឡើយដែលមន្ត្រីសុរិយោដីមានកាតព្វកិច្ចចុះបញ្ជី ទាំងពុំមានពាក្យសុំពីភាគី។

[7] តុលាការត្រូវសម្រេចអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី (មាត្រា ១៨២ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ហើយ ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់ភាគីចាញ់ក្តី (មាត្រា ៦៤ កថាខណ្ឌទី ១)។

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ

**ស្តីអំពីការបង្កើតកិច្ចសន្យាលក់ទិញ** [8]

**ខ.១.** នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ ដើមចោទបានទិញអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L") ក្នុងតម្លៃ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិកពីចុងចម្លើយ(តទៅនេះហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ) ។ **( ភស្តុតាង $X_1$)**

**ខ.២.** "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានធ្វើឡើងជាលិខិតយថាភូត។ **( ភស្តុតាង $X_1$)**

**ដូច្នេះ ដើមចោទទាមទារឲ្យចុងចម្លើយ ប្រគល់ដី L និង ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកលើ " កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ " ។** [9]

## គ.អង្គហេតុពាក់ព័ន្ធ

**គ.១.** នៅក្នុង "កិច្ចសន្យានៃរឿងក្តីនេះ" បានកំណត់ថា នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៨ ចុងចម្លើយត្រូវប្រគល់ដី L និង ធ្វើនីតិវិធីចុះបញ្ជី ជាថ្នូរនឹងដើមចោទបង់ប្រាក់ ២០០.០០០ (ពីរសែន) ដុល្លារអាមេរិក។

**គ.២.** យ៉ាងណាមិញ នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ចុងចម្លើយបានយកប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិកមកផ្ទះរបស់ដើមចោទ

[8] អង្គហេតុចម្បងនៃ ① ការទាមទារឲ្យប្រគល់វត្ថុនៃការលក់ទិញ និង ② សិទ្ធិទាមទារឲ្យធ្វើនិតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំង មូលដោយផ្អែកលើកិច្ចសន្យាលក់ទិញរួមមាន ៖ មាត្រា ៥១៥ មាត្រា ៥១៦ មាត្រា ៥៣០ និង កថាខណ្ឌទី ១ មាត្រា ៥៣១នៃក្រមរដ្ឋប្បវេណី។ តាមរយៈការបង្កើតកិច្ចសន្យាលក់ទិញ នឹងនាំឲ្យកើតមាននូវសិទ្ធិទាមទារ ① និង ② ដូច្នេះហើយជាដំបូងចាំបាច់ត្រូវធ្វើការអះអាងអំពីការចុះកិច្ចសន្យា។

ម្យ៉ាងវិញទៀត ចំពោះកិច្ចសន្យា ① ខាងលើនេះ ក្នុងករណីដែល "ភាគីម្ខាងធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ" ប្រសិនបើមិនធ្វើជាលិខិតយថាភូតទេ កិច្ចសន្យានេះនឹងមិនមានអានុភាពទេ (មាត្រា ៣៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី)។ លើសពីនេះទៀតចំពោះ "លិខិតយថាភូត" នៃកថាខណ្ឌទី២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី មានចែងនៅក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៩ កថាខណ្ឌទី ១។

[9] បញ្ជាក់ឲ្យបានច្បាស់អំពីមូលដ្ឋានគតិយុត្ត។

ហើយបានអះអាងតែម្នាក់ឯងថា "នឹងរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដោយសារតែរកបានអ្នកទិញដី L ក្នុងតម្លៃខ្ពស់ជាងនេះ" ជាអាទិ៍ រួចហើយទើបត្រឡប់ទៅផ្ទះវិញ។

## ឃ. ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីនៃរឿងក្តីនេះ គប្បីជាបន្ទុករបស់ចុងចម្លើយ។ (មាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## ង. ភស្តុតាង

១.លិខិតយថាភូតស្តីពីការលក់ទិញ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨ (**ភស្តុតាង**$X_1$)

សេចក្តីដូចមានកំណត់ សូម **លោកប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។ សូម **លោកប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

ឯកសារភ្ជាប់

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

**ឧបសម្ព័ន្ធ**

# **បញ្ជី**[10]

| | |
|---|---|
| "គោលបំណងនៃពាក្យសុំចុះបញ្ជី" | ផ្ទេរកម្មសិទ្ធិទាំងមូល |
| "មូលហេតុនៃពាក្យសុំចុះបញ្ជី និង កាលបរិច្ឆេទ" | ការលក់ទិញចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៨ |
| "បុគ្គលមានសិទ្ធិចុះបញ្ជី" | ដើមចោទ ( X )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ ......................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ...................(ឪពុក)<br>.....................(ម្តាយ) |
| "បុគ្គលមានកាតព្វកិច្ចចុះបញ្ជី" | ចុងចម្លើយ ( Y )<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ ......................................<br>ឈ្មោះរបស់ឪពុកម្តាយ៖ ...................(ឪពុក)<br>.....................(ម្តាយ) |
| "អត្តសញ្ញាណនៃអចលនវត្ថុ" | ទីតាំងដី ៖ ផ្លូវលេខ ១០២ ភូមិ ៣ សង្កាត់ ជ្រោយចង្វារ ខណ្ឌ ជ្រោយចង្វារ រាជធានី ភ្នំពេញ<br>លេខក្បាលដី ៖ ១៣០៦ |

[10] ដើម្បីទាមទារនូវនីតិវិធីចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ មានភាពចាំបាច់ត្រូវសរសេរអំពីចំណុចដែលត្រូវបានកំណត់នៅក្នុងប្រការ ២៦ និង ២៨ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី។